# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ ២៨០ ព្រ.ទ ៦១០៦-៩៤

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

-លោកប្រធានតុលាការ ខេត្ត ក្រុង

-លោកព្រះរាជអាជ្ញាអមតុលាការ ខេត្ត ក្រុង

<u>សូមជ្រាប។</u>

**<u>កម្មវត្ថុ</u>**: សេចក្តីណែនាំអំពីចំណាត់ការលើសំណុំរឿងបទល្មើសព្រៃឈើ ។

ខ្ញុំសូមជម្រាបលោកថា នៅពេលកន្លងទៅថ្មីៗនេះក្រសួងយុត្តិធម៌បានទទួលលិខិតផ្ទួនៗពីក្រសួងកសិកម្មរុក្ខាប្រមាញ់ស្តីពីតុលាការ ខេត្ត ក្រុងមួយចំនួនពុំព្រមលើកយកសំណុំរឿងបទល្មើសព្រៃឈើមកធ្វើការជំនុំជម្រះឲ្យបានទាន់ពេលវេលា ។

បញ្ហានេះក្រសួងបានពិនិត្យឃើញថា មានសំណុំរឿងបទល្មើសព្រៃឈើខ្លះមាននៅសល់តាំងពីឆ្នាំ១៩៩០មកម្លេះ ដែលតុលាការខេត្ត ក្រុង មួយចំនួនពុំបានលើកយកមកធ្វើការជំនុំជម្រះ ។

ដើម្បីជៀសវាងកុំឲ្យមានការកកស្ទះសំណុំរឿងប្រភេទនេះតទៅទៀត ក្រសួងសូមលោកប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុងលើកយកសំណុំរឿងបទល្មើសព្រៃឈើដែលមាននៅសល់ទាំងប៉ុន្មានមកធ្វើការជំនុំជម្រះឲ្យបានឆាប់។ បើសំណុំរឿងទាំងនោះពុំទាន់មានធាតុផ្សំគ្រប់គ្រាន់នៅឡើយទេគួរបង្វិលសំណុំរឿងទាំងនោះទៅឲ្យនាយកដ្ឋានរុក្ខាប្រមាញ់ ដើម្បីស៊ើបអង្កេតបំពេញបន្ថែមឲ្យបានគ្រប់ជ្រុងជ្រោយជាបន្ទាន់ រួចហើយចាត់ការតាមច្បាប់តទៅ ។

ចំពោះបទល្មើសជលផល និងគយក៏ត្រូវអនុវត្តឲ្យបានទាន់ពេលដូចការណែនាំនេះដែរ ។

តែហើតុលាការបានអញ្ជើញតំណាងក្រសួងកសិកម្មណ និងរុក្ខាប្រមាញ់ចូលមកតុលាការដើម្បីចាត់ការរឿងនោះ ហើយពុំមានតំណាងណាមួយចូលរួមទេ ដែលជាមូលហេតុនាំឲ្យរឿងនៅកកស្ទះ នោះសូមរាយការណ៍មកក្រសួងយុត្តិធម៌ដើម្បីក្រសួងយុត្តិធម៌ជម្រាបទៅក្រសួងពាក់ព័ន្ធ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៤

រដ្ឋមន្ត្រី

**ចែម ស្គួន**

<u>ចម្លងជូន</u>

-តុលាការកំពូល

-មហាអយ្យការ អមតុលាការកំពូល

-ក្រសួងកសិកម្មរុក្ខា ប្រមាញ់

-ដើម្បីជ្រាបជាពត៌មាន